**មាត្រា ៣** : លក្ខខ័ណ្ឌក្នុងការសុំលេខទិដ្ឋាការៈបញ្ជីការឱសថ ត្រូវកំណត់ដោយក្រសួងសុខាភិបាល ។

**មាត្រា ៤** : ឱសថដែលបានទទួលលេខទិដ្ឋាការ ឬ បញ្ជីការឱសថពីក្រសួងសុខាភិបាល ត្រូវបង់សោហ៊ុយតាមការកំណត់របស់ក្រសួងសុខាភិបាល ។

**មាត្រា ៥** : ការត្រួតពិនិត្យការផ្តល់ និង ការដកហូតវិញនូវលេខទិដ្ឋាការ ឬ បញ្ជីការឱសថជាសមត្ថកិច្ចរបស់ក្រសួងសុខាភិបាល ។

**មាត្រា ៦** : បទបញ្ញត្តិទាំងឡាយណាដែលផ្ទុយពីអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ៧** : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសុខាភិបាល មានភារកិច្ចអនុវត្តអនុក្រឹត្យនេះអោយមានប្រសិទ្ធិភាពតាមភារកិច្ចរៀងៗខ្លួន ។

**មាត្រា ៨** : អនុក្រឹត្យនេះមានអានុភាពជាធរមានគតិយុត្តិ ចាប់ពីថ្ងៃឡាយព្រះហស្តលេខា និង ចុះហត្ថលេខាតទៅ ។

| នាយករដ្ឋមន្ត្រីទី ១ | នាយករដ្ឋមន្ត្រីទី ២ |
|---|---|
| ព្រះហស្តលេខា និង ត្រា | ហត្ថលេខា និង ត្រា |
| **នរោត្តម រណឫទ្ធិ** | **ហ៊ុន សែន** |

***

*រាជធានីភ្នំពេញ , ថ្ងៃទី ១២ ខែ សីហា ឆ្នាំ ១៩៩៤*

## អនុក្រឹត្យលេខ ៤៥ អនក្រ
## ស្តីពីនិយ័តភាពគណធានរបស់អាជ្ញាធរ
## អាកាសចរស៊ីវិលកម្ពុជា ពីជំពូក ១១ មកជំពូក ១០

រាជរដ្ឋាភិបាលកម្ពុជា

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ នរោត្តម សីហនុ វរ្ម័ន ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា

-បានឃើញច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ ០១ នស ចុះថ្ងៃទី ២៨ ខែ ធ្នូ ១៩៩៣

-បានឃើញច្បាប់ហិរញ្ញវត្ថុ សំរាប់ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើដោយព្រះរាជក្រម លេខ ០២ នស ចុះថ្ងៃទី ២៨ខែធ្នូ ឆ្នាំ ១៩៩៣

-បានឃើញអនុក្រឹត្យ លេខ ០១ អនក្រ ចុះថ្ងៃទី ០៥ ខែ មករា ឆ្នាំ ១៩៩៤ ស្តីពីការបែងចែកឥណទានតាមជំពូកនៃច្បាប់ហិរញ្ញវត្ថុសំរាប់ឆ្នាំ ១៩៩៤

-តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

## សំរេច

**មាត្រា ១** : អនុញ្ញាតអោយធ្វើនិយ័តកម្មឥណទាន ឆ្នាំ ១៩៩៤ របស់អាជ្ញាធរអាកាសចរស៊ីវិលកម្ពុជាចំនួន ១៨០.០០០.០០០៛ ( មួយរយប៉ែតសិបលានរៀលគត់ ) ពី :

**ជំពូក ១១**

-ប្រភេទ ០១ : ចំណាយសំភារៈ និង គ្រប់គ្រងរដ្ឋបាល

-កថាខ័ណ្ឌ ១៤ : ចំណាយដោយឡែករបស់ផ្នែក

-វាក្យខ័ណ្ឌ ០១ : ឈ្នួលស្នាក់ការរដ្ឋបាល

**បញ្ចូលទៅក្នុងជំពូក ១០**

-ប្រការ ០២ : បៀវត្ស និង ប្រាក់បំណាច់បុគ្គលិក ក្របខ័ណ្ឌអចិន្ត្រៃយ៍

-កថាខ័ណ្ឌ ០៣ : ប្រាក់បំណាច់ផ្សេងៗ

-វាក្យខ័ណ្ឌ ០២ : ប្រាក់បំណាច់ម៉ោងបន្ថែម

**មាត្រា ២** : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ អនុរដ្ឋលេខាធិការអាជ្ញាធរអាកាសចរស៊ីវិលកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃឡាយព្រះហស្តលេខា និង ចុះហត្ថលេខាតទៅ។

| | |
|---|---|
| នាយករដ្ឋមន្ត្រីទី ១ | នាយករដ្ឋមន្ត្រីទី ២ |
| ព្រះហស្តលេខា និង ត្រា | ហត្ថលេខា និង ត្រា |
| **នរោត្តម រណឫទ្ធិ** | **ហ៊ុន សែន** |

***

រាជធានីភ្នំពេញ ថ្ងៃទី ១២ ខែ សីហា ឆ្នាំ ១៩៩៤

# អនុក្រឹត្យលេខ ៤៦ អនក្រ
# ស្តីពីការធ្វើនិយ័តភាពថវិកាឆ្នាំ ១៩៩៤ របស់ក្រសួង
# ឧស្សាហកម្មរ៉ែ និងថាមពលពីជំពូក ៥១ មកបំពេញអោយជំពូក ៥២

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ នរោត្តម សីហនុ វរ្ម័ន ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញច្បាប់ស្តីអំពីប្រព័ន្ធហិរញ្ញវត្ថុ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ ០១ នស ចុះថ្ងៃទី ២៨ខែ ធ្នូ ឆ្នាំ ១៩៩៣
- បានឃើញច្បាប់ហិរញ្ញវត្ថុសំរាប់ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ ០២ នស ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣
- បានឃើញអនុក្រឹត្យលេខ ០១ អនក្រ ចុះថ្ងៃទី ០៥ ខែ មករា ឆ្នាំ ១៩៩៤ ស្តីពីការបែងចែកឥណទានតាមជំពូក នៃច្បាប់ហិរញ្ញវត្ថុសំរាប់ឆ្នាំ ១៩៩៤
- យោងតាមសំណើរបស់ទេសរដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

## សំរេច

**មាត្រា ១ :** អនុញ្ញាតអោយធ្វើនិយ័តភាពថវិកា ឆ្នាំ ១៩៩៤ របស់ក្រសួងឧស្សាហកម្មរ៉ែ និង ថាមពលចំនួនទឹកប្រាក់ ៧០០.០០០.០០០រ០០ ( ប្រាំពីររយលានគត់ ) ពី ជំពូក ៥១ ឥណទានទទួលសំការៈមកបំពេញអោយជំពូក ៥២ ប្រតិបត្តិការហិរញ្ញវត្ថុ សំរាប់ផ្តល់ជូនក្រុមហ៊ុនក្រចៅផ្ទនទារ ខេត្តបាត់ដំបង ។

**មាត្រា ២ :** សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងឧស្សាហកម្មរ៉ែនិង ថាមពល ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខា និង ចុះហត្ថលេខាតទៅ ។

នាយករដ្ឋមន្ត្រីទី ១ នាយករដ្ឋមន្ត្រីទី ២

ព្រះហស្តលេខា និង ត្រា ហត្ថលេខា និង ត្រា

**នរោត្តម រណឫទ្ធិ ហ៊ុន សែន**

***

ធ្វើនៅភ្នំពេញ ថ្ងៃទី ១២ ខែ សីហា ឆ្នាំ ១៩៩៤

# អនុក្រឹត្យលេខ ៨៦ អនក្រ

# ស្តីពីការតែងតាំងមន្ត្រីរាជការ

រាជរដ្ឋាភិបាលកម្ពុជា

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ នរោត្តម សីហនុ វរ្ម័ន ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែវិច្ឆិកា ឆ្នាំ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា

-តាមសំណើរបស់ឯកឧត្តមរដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

**សំរេច**

**មាត្រា ១ : តែងតាំង**

១-លោក **គុយ ចេង្គ៉ា** ជាប្រធានអគ្គនាយកដ្ឋានចំការកៅស៊ូ

២-លោក **ខួន ផនស៊ីផុន** ជាអនុប្រធានអគ្គនាយកដ្ឋានចំការកៅស៊ូ

៣-លោក **អ៊ុំ គីហ៊ាង** ជាអនុប្រធានអគ្គនាយកដ្ឋានចំការកៅស៊ូ

៤-លោក **លី ផល្លា** ជាអនុប្រធានអគ្គនាយកដ្ឋានចំការកៅស៊ូ

**មាត្រា ២ :** សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រីក្រសួង សេដ្ឋកិច្ច និង ហិរញ្ញវត្ថុ អនុរដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ និងសាមីជនត្រូវទទួលអនុវត្តតាមអនុក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខា និងចុះហត្ថលេខាតទៅ ។

នាយករដ្ឋមន្ត្រីទី ១ នាយករដ្ឋមន្ត្រីទី ២

ព្រះហស្តលេខា និង ត្រា ហត្ថលេខា និង ត្រា

**នរោត្តម រណឫទ្ធិ ហ៊ុន សែន**